ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គោលការណ៍ណែនាំ

## ស្តីពី

## ការចូលរួមវគ្គបណ្តុះបណ្តាលនិងការប្រឡងគុណវុឌ្ឍិ
## និងកម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យមូលបត្រ

ចែករំលែកដោយៈ

សមាគមឈ្មួញជើងសាឧបករណ៍និស្សន្ទនៅកម្ពុជា

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**

លេខៈ ០០១/១៩..........គ.ម.ក./គ.លា.ន

*ថ្ងៃព្រហស្បតិ៍ ១២ កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២*

*រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៩*

# គោលការណ៍ណែនាំ

## ស្តីពី

## ការចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ និងកម្មវិធីអប់រំវិជ្ជាជីវៈបន្ត ក្នុងវិស័យមូលបត្រ

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, អនុក្រឹត្យលេខ៥៤ អនក្រ.បក. ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, ប្រកាសលេខ ០០២ គ.ម.ក. ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីអភិបាលកិច្ចសាជីវកម្ម សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ, ប្រកាសលេខ ០១៧/១០ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០ ស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់សហគ្រាសសាធារណៈបោះផ្សាយលក់មូលបត្រជាសាធារណៈ, ប្រកាសលេខ ០០៤/១៥ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ, ប្រកាសលេខ ០០១ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មមូលបត្រ, ប្រកាសលេខ ០០២/១៨ គ.ម.ក. /ប្រ.ក. ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការទទួលស្គាល់ភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ, ប្រកាសលេខ ០០៣/១៨ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មគម្រោងវិនិយោគរួម, ប្រកាសលេខ ០០៥/១៨ គ.ម.ក. /ប្រ.ក. ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីការផ្តល់ការអនុញ្ញាតដល់ក្រុមហ៊ុនចែកចាយលក់មូលបត្រ និងភ្នាក់ងារចែកចាយលក់មូលបត្រ ប្រកាសលេខ ០០៧/១៨ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបង្ហាញព័ត៌មានសាជីវកម្មព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀត និងដើម្បីសម្រួលដល់ការយល់ដឹង និងធានាឱ្យបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាព គណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**) សម្រេចចេញគោលការណ៍ណែនាំស្តីពីការចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ និងកម្មវិធីអប់រំវិជ្ជាជីវៈបន្ត ដូចខាងក្រោម÷

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh Website : www.secc.gov.kh

### ១-លក្ខខណ្ឌក្នុងការចូលរួមវគ្គបណ្តុះបណ្តាលគុណវុឌ្ឍិដំបូង

អភិបាល និងបុគ្គលិករបស់ក្រុមហ៊ុនបោះផ្សាយ ឬក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណ ការអនុញ្ញាត ឬការទទួលស្គាល់ ឬទទួលបានការអនុញ្ញាតជាគោលការណ៍ពី **គ.ម.ក.** និងមេធាវីផ្តល់សេវាក្នុងវិស័យមូលបត្រ ដែលត្រូវចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិដំបូង ត្រូវដាក់ជូន **គ.ម.ក.** នូវឯកសារដូចខាងក្រោម÷

- ពាក្យស្នើសុំចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ ១ (មួយ) ច្បាប់តាមទម្រង់ធី-១ (FormT-1) ដោយបិទរូបថតទំហំ ៤x៦ ចំនួន ១សន្លឹក និងភ្ជាប់រូបថតទំហំ ៤x៦ ចំនួន១ សន្លឹក (មិនលើសពី ៦ ខែ)
- លិខិតចាត់តាំងពីក្រុមហ៊ុន
- អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនថតចម្លងចំនួន ១ (មួយ) ច្បាប់
- បង្កាន់ដៃបង់ថ្លៃចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងតាមការកំណត់របស់**គ.ម.ក.**
- ឯកសារតម្រូវផ្សេងៗទៀតតាមការកំណត់របស់អគ្គនាយកនៃ **គ.ម.ក.**។

បុគ្គលដែល **គ.ម.ក.** តម្រូវឱ្យចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ ត្រូវដាក់ពាក្យស្នើសុំ និងឯកសារភ្ជាប់សម្រាប់ចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានលិខិតតម្រូវឱ្យចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិពី **គ.ម.ក.**។

សាធារណជនទូទៅដែលមានបំណងចូលរួមវគ្គបណ្តុះបណ្តាលនិងការប្រឡងគុណវុឌ្ឍិដំបូងត្រូវដាក់ជូន **គ.ម.ក.** នូវឯកសារដូចខាងក្រោម÷

- ពាក្យស្នើសុំចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ ១ (មួយ) ច្បាប់តាមទម្រង់ធី-១ (FormT-1) ដោយបិទរូបថតទំហំ ៤x៦ ចំនួន ១សន្លឹក និងភ្ជាប់រូបថតទំហំ ៤x៦ ចំនួន ១ សន្លឹក (មិនលើសពី ៦ ខែ)
- អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនថតចម្លងចំនួន ១ (មួយ) ច្បាប់
- សញ្ញាបត្រថតចម្លងចំនួន ១ (មួយ) ច្បាប់
- បង្កាន់ដៃបង់ថ្លៃចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងតាមការកំណត់របស់**គ.ម.ក.**
- ឯកសារតម្រូវផ្សេងៗទៀតតាមការកំណត់របស់អគ្គនាយកនៃ **គ.ម.ក.**។

### ២-លក្ខខណ្ឌក្នុងការចូលរួមការប្រឡងគុណវុឌ្ឍិ

ការប្រឡងគុណវុឌ្ឍិ ត្រូវរៀបចំឡើងក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាលគុណវុឌ្ឍិនីមួយៗ ឬក្នុងរយៈពេលណាមួយតាមការកំណត់របស់អគ្គនាយកនៃ **គ.ម.ក.**។ បុគ្គលដែលអាចចូលរួមការប្រឡងគុណវុឌ្ឍិបាន លុះត្រាតែបុគ្គលនោះបានចូលរួមវគ្គបណ្តុះបណ្តាលគុណវុឌ្ឍិដែលរៀបចំដោយ **គ.ម.ក.** ឬដោយស្ថាប័នបណ្តុះបណ្តាលដែលទទួលបានសិទ្ធិពី **គ.ម.ក.** ដោយត្រូវមានវត្តមានយ៉ាងតិច ៦០ % (ហុកសិបភាគរយ)។

ករណីខកខានមិនបានចូលរួមការប្រឡងគុណវុឌ្ឍិជាលើកទី១ បុគ្គលដែលបានចូលរួមវគ្គបណ្តុះបណ្តាលគុណវុឌ្ឍិនោះ ត្រូវចូលរួមការប្រឡងគុណវុឌ្ឍិតាមការកំណត់របស់ **គ.ម.ក.** ដោយត្រូវបង់ថ្លៃចូលរួមវគ្គបណ្តុះ-បណ្តាល និងការប្រឡងគុណវុឌ្ឍិសារជាថ្មីតាមការកំណត់របស់ **គ.ម.ក.** ដើម្បីទទួលបានសិទ្ធិចូលរួមការប្រឡងគុណវុឌ្ឍិ។

ករណីខកខានមិនបានចូលរួមការប្រឡងគុណវុឌ្ឍិជាលើកទី ២ បុគ្គលដែលបានចូលរួមវគ្គបណ្តុះបណ្តាលគុណវុឌ្ឍិនោះត្រូវដាក់ពាក្យស្នើសុំ និងឯកសារភ្ជាប់ដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ ដើម្បីចូលរួមវគ្គបណ្តុះ-បណ្តាល និងការប្រឡងគុណវុឌ្ឍិសារឡើងវិញ។

សុពលភាពនៃលទ្ធផលប្រឡងគុណវុឌ្ឍិមានរយៈពេល ២ (ពីរ) ឆ្នាំគិតចាប់ពីកាលបរិច្ឆេទដែល **គ.ម.ក.** ប្រកាសលទ្ធផលប្រឡង។ បុគ្គលដែលមានបំណង ឬ ត្រូវបន្តសុពលភាពលទ្ធផលប្រឡងគុណវុឌ្ឍិ ត្រូវដាក់ពាក្យស្នើសុំចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្ត និងដាក់ឯកសារភ្ជាប់មក **គ.ម.ក.** ឱ្យបាន ១ (មួយ) ខែមុនពេលលទ្ធផលប្រឡងគុណវុឌ្ឍិអស់សុពលភាព។

## ៣-កម្មវិធីអប់រំវិជ្ជាជីវៈបន្ត

បុគ្គលដែលមានបំណង ឬ ត្រូវចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្ត ត្រូវដាក់ពាក្យស្នើសុំចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្ត និងដាក់ឯកសារភ្ជាប់មក **គ.ម.ក.** ឱ្យបាន ១ (មួយ) ខែ មុនពេលលទ្ធផលប្រឡង ឬ លទ្ធផលនៃកម្មវិធីអប់រំវិជ្ជាជីវៈបន្ត អស់សុពលភាព។

បុគ្គលដាក់ពាក្យស្នើសុំត្រូវផ្តល់ជូន **គ.ម.ក.** នូវឯកសារដូចខាងក្រោម÷

ក- ពាក្យស្នើសុំចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្តតាមទម្រង់ធ-២ (Form T-2)

ខ- លិខិតចាត់តាំងពីក្រុមហ៊ុន សម្រាប់បុគ្គលដែលត្រូវចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្ត

គ- បង្កាន់ដៃបង់ប្រាក់ចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្តតាមការកំណត់របស់ **គ.ម.ក.**

ករណីយឺតយ៉ាវក្នុងការដាក់ពាក្យ ឬ ខកខានមិនបានចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្តលើកទី១ បុគ្គលត្រូវចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្ត និងត្រូវបង់ថ្លៃចូលរួមតាមការកំណត់របស់ **គ.ម.ក.** ដោយសុពលភាពគុណ-វុឌ្ឍិត្រូវរាប់ចាប់ពីថ្ងៃផុតកំណត់នៃសុពលភាពចាស់។

ករណីខកខានមិនបានចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្តជាលើកទី២ បុគ្គលដែលត្រូវចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្ត ត្រូវដាក់ពាក្យស្នើសុំ និងដាក់ឯកសារភ្ជាប់ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃចំណុចទី ១ ខាងលើ ដើម្បីចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិសារឡើងវិញ។

បុគ្គលដែលចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្ត ត្រូវមានវត្តមានក្នុងកម្មវិធីយ៉ាងតិច ៨០% (ប៉ែតសិបភាគរយ)។

សុពលភាពនៃការចូលរួមវិធីអប់រំវិជ្ជាជីវៈបន្ត មានរយៈពេល ០២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទ ដែល **គ.ម.ក.** ប្រកាសលទ្ធផលនៃការប្រឡងគុណវុឌ្ឍិ ឬ ប្រកាសលទ្ធផលនៃការចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្ត។

ស្នាម

**៤-លទ្ធផលធ្លាក់ស្វ័យប្រវត្តិ**

ត្រូវទទួលលទ្ធផលធ្លាក់ដោយស្វ័យប្រវត្តិ ក្នុងករណីបុគ្គល÷

ក- បង្កឱ្យមានបញ្ហា ឬ ភាពមិនប្រក្រតីក្នុងអំឡុងពេលចូលរួមវគ្គបណ្តុះបណ្តាល ឬ ការប្រឡងគុណវុឌ្ឍិ ឬ កម្មវិធីអប់រំវិជ្ជាជីវៈបន្ត

ខ- មិនមានវត្តមានចូលរួមវគ្គបណ្តុះបណ្តាល ឬ ការប្រឡងគុណវុឌ្ឍិ ឬ កម្មវិធីអប់រំវិជ្ជាជីវៈបន្តបានពេញលេញតាមការកំណត់របស់ **គ.ម.គ.**។

**៥-ការដកប្រាក់វិញ**

ប្រាក់ដែលបានបង់ចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ ឬកម្មវិធីអប់រំវិជ្ជាជីវៈបន្ត មិនត្រូវបានប្រគល់ជូនវិញឡើយ។៚

**គណៈកម្មការមូលបត្រកម្ពុជា**